នីតិវិធីស្នើសុំជំនួយគតិយុត្តិ

តាមមាត្រា ២៩ នៃច្បាប់ស្តីពីជំនួយគតិយុត្តិ ជនជាតិភាគតិចត្រូវរៀបចំសំណុំឯកសារស្នើសុំជំនួយគតិយុត្តិ រួមមាន៖



- ពាក្យស្នើសុំជំនួយគតិយុត្តិ (តាមទម្រង់ដែលផ្តល់ជូននៅឯអង្គការអនុវត្តជំនួយគតិយុត្តិ ឬទាញយកនៅគេហទំព័រសេវាសាធារណៈជាតិ នីតិវិធីស្នើសុំជំនួយគតិយុត្តិ - លេខកូដ 2.0000829)។



- លិខិតស្នាមបញ្ជាក់ថាជាជនជាតិភាគតិចដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិ។



- លិខិតស្នាម និងឯកសារនានាដែលពាក់ព័ន្ធនឹងរឿងក្តីជំនួយគតិយុត្តិ។

TRỢ GIÚP PHÁP LÝ

វិធីសាស្ត្រដាក់ឯកសារស្នើសុំជំនួយគតិយុត្តិ៖



ដាក់ស្នើសំណុំឯកសារដោយផ្ទាល់នៅទីស្នាក់ការមជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ឬអង្គការដែលចូលរួមជំនួយគតិយុត្តិ។



ផ្ញើសំណុំឯកសារតាមរយៈសេវាប្រៃសណីយ៍។



ផ្ញើសំណុំឯកសារតាមរយៈហ្វាក់ស៍ ឬទម្រង់អេឡិចត្រូនិក។

:អាសយដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានប្រកាសជាសាធារណៈនៅ៖

- **គេហទំព័រនីតិកម្មជាតិ**
  https://phapluat.gov.vn/
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់ក្រសួងយុត្តិធម៌**
  https://dstrogiupphaply.moj.gov.vn/all/searchOrganization
- **គេហទំព័រព័ត៌មានអេឡិចត្រូនិកស្តីពីជំនួយគតិយុត្តិនៅប្រទេសវៀតណាម**
  https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx
- **គេហទំព័រព័ត៌មានអេឡិចត្រូនិករបស់មន្ទីរយុត្តិធម៌នៅមូលដ្ឋាន**



ខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីជំនួយគតិយុត្តិ

១៨០០១២៣៣

(Cước gọi miễn phí)

ទាញយកកម្មវិធីទូរស័ព្ទចល័តស្តីពីជំនួយគតិយុត្តិ

កូដ *QR* សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ *Android*

កូដ *QR* សម្រាប់ទាញយកកម្មវិធីលើប្រព័ន្ធ *iOS*

BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិដោយឥតគិតថ្លៃ សម្រាប់ជនជាតិភាគតិច

TRỢ GIÚP PHÁP LÝ



តើជំនួយគតិយុត្តិជាអ្វី?

គឺជាការផ្តល់សេវាគតិយុត្តិដោយឥតគិតថ្លៃ ជូនអ្នកទទួលបានជំនួយគតិយុត្តិ ក្នុងរឿងក្តីជំនួយគតិយុត្តិ ស្របតាមបទបប្បញ្ញត្តិនៃច្បាប់ស្តីពីជំនួយគតិយុត្តិ ដោយចូលរួមធានានូវសិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ ក្នុងការទទួលបានយុត្តិធម៌ និងសមភាពនៅចំពោះមុខច្បាប់។

(មាត្រា ២ នៃច្បាប់ស្តីពីជំនួយគតិយុត្តិ)

ជនជាតិភាគតិចដែលស្ថិតក្នុងករណីដូចខាងក្រោម ទទួលបានជំនួយគតិយុត្តិដោយឥតគិតថ្លៃ៖

1. អ្នកមានសគុណចំពោះបដិវត្តន៍។
2. អ្នកស្ថិតក្នុងក្របខណ្ឌគ្រួសារក្រីក្រ។
3. កុមារ។
4. ជនជាតិភាគតិចដែលរស់នៅតំបន់មានស្ថានភាពសេដ្ឋកិច្ច - សង្គមលំបាកជាពិសេស។
5. អ្នកដែលមានអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ក្នុងករណីជាអ្នកត្រូវចោទប្រកាន់ អ្នកត្រូវបានស្នើឲ្យប្តឹង អ្នកត្រូវបានឃាត់ខ្លួនក្នុងករណីបន្ទាន់ អ្នកចុងចោទ ជនរងគ្រោះ សាក្សី អ្នកដែលកំពុងស្ថិតក្រោមការអនុវត្តវិធានការដោះស្រាយបង្វែរទិស និងជាទណ្ឌិតក្នុងនីតិវិធីព្រហ្មទណ្ឌ។
6. អ្នកចុងចោទដែលស្ថិតក្នុងក្របខ័ណ្ឌគ្រួសារបៀតក្រីក្រ។
7. អ្នករងគ្រោះអ្នកដែលកំពុងស្ថិតក្នុងដំណើរការកំណត់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកដែលមានអាយុក្រោម ១៨ ឆ្នាំរួមដំណើរជាមួយស្របតាមបទបប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស។
8. អ្នកស្ថិតក្នុងករណីមួយក្នុងចំណោមករណីដូចខាងក្រោមនេះ មានការលំបាកអំពីហិរញ្ញវត្ថុ៖ *i)* ឪពុកបង្កើត ម្តាយបង្កើត ប្តី ប្រពន្ធ កូនរបស់យុទ្ធជនពលី និងអ្នកមានគុណបំណាច់ក្នុងការចិញ្ចឹមបីបាច់យុទ្ធជនពលីកាលពីនៅតូច; *ii)* អ្នកដែលរងផលប៉ះពាល់ដោយសារធាតុពុលពណ៌ទឹកក្រូច; *iii)* មនុស្សចាស់; *iv)* ជនមានពិការភាព; *v)* ជនរងគ្រោះក្នុងករណីអំពើហិង្សាគ្រួសារ; *vi)* អ្នកជ្រាប *HIV*។

លក្ខខណ្ឌលំបាកអំពីហិរញ្ញវត្ថុរបស់អ្នកដែលស្ថិតក្នុងករណីខាងលើ គឺជាអ្នកស្ថិតក្នុងគ្រួសារបៀតក្រីក្រ ឬជាអ្នកដែលកំពុងទទួលប្រាក់ឧបត្ថម្ភសង្គមប្រចាំខែ ស្របតាមបទបប្បញ្ញត្តិនៃច្បាប់។

សិទ្ធិរបស់ជនជាតិភាគតិចដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិដោយឥតគិតថ្លៃពីរដ្ឋ

ជនជាតិភាគតិចដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិ មានសិទ្ធិដូចខាងក្រោម៖

ទទួលបានជំនួយគតិយុត្តិ ដោយមិនបាច់បង់ប្រាក់ ផលប្រយោជន៍សម្ភារៈ ឬផលប្រយោជន៍ផ្សេងទៀត (ឥតគិតថ្លៃ)។



ស្នើសុំជំនួយគតិយុត្តិ ដោយខ្លួនឯង ឬតាមរយៈសាច់ញាតិ ស្ថាប័ន អ្នកមានសមត្ថកិច្ចដំណើរការនីតិវិធីតុលាការ ឬស្ថាប័ន អង្គការបុគ្គលដទៃទៀត។



ត្រូវបានផ្តល់ព័ត៌មានអំពីសិទ្ធិទទួលបានជំនួយគតិយុត្តិ លំដាប់ និងនីតិវិធីនៃជំនួយគតិយុត្តិ នៅពេលទៅដល់អង្គការអនុវត្តជំនួយគតិយុត្តិ និងស្ថាប័នរដ្ឋពាក់ព័ន្ធ។



សុំឲ្យរក្សាការសម្ងាត់អំពីខ្លឹមសារនៃរឿងក្តីជំនួយគតិយុត្តិ។



ជ្រើសរើសអង្គការអនុវត្តជំនួយគតិយុត្តិ និងអ្នកអនុវត្តជំនួយគតិយុត្តិនៅមូលដ្ឋាន ក្នុងបញ្ជីដែលបានផ្សព្វផ្សាយ។ ស្នើសុំប្តូរអ្នកអនុវត្តជំនួយគតិយុត្តិ នៅពេលអ្នកនោះស្ថិតក្នុងករណីណាមួយ ដែលបញ្ញត្តិនៅប្រការ ១ និងប្រការ ២ មាត្រា ២៥ នៃច្បាប់ស្តីពីជំនួយគតិយុត្តិ។



ផ្លាស់ប្តូរ ឬដកពាក្យស្នើសុំជំនួយគតិយុត្តិ។



ទទួលបានសំណងការខូចខាត ស្របតាមបទបប្បញ្ញត្តិច្បាប់។



ធ្វើពាក្យបណ្តឹង និងបណ្តឹងចោទប្រកាន់អំពីជំនួយគតិយុត្តិ ស្របតាមបទបប្បញ្ញត្តិនៃច្បាប់នេះ និងបទបប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ។

អង្គការអនុវត្តជំនួយគតិយុត្តិដោយឥតគិតថ្លៃ សម្រាប់ជនជាតិភាគតិច៖



- មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ក្រោមឱវាទមន្ទីរយុត្តិធម៌ខេត្ត និងក្រុងក្រោមឱវាទថ្នាក់កណ្តាល ត្រង់កន្លែងដែលអ្នកទទួលបានជំនួយគតិយុត្តិកំពុងរស់នៅ។
- មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ក្រោមឱវាទមន្ទីរយុត្តិធម៌ ត្រង់កន្លែងកើតរឿងក្តី។
- អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលបានចុះកិច្ចសន្យា ឬចុះឈ្មោះចូលរួមជំនួយគតិយុត្តិ ស្របតាមបទបប្បញ្ញត្តិច្បាប់។

អ្នកអនុវត្តជំនួយគតិយុត្តិដោយឥតគិតថ្លៃ សម្រាប់ជនជាតិភាគតិច៖

ភ្នាក់ងារជំនួយគតិយុត្តិ (ជាមន្ត្រីកិច្ចសន្យាសាធារណៈ ក្រោមមជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ)។

មេធាវីដែលអនុវត្តជំនួយគតិយុត្តិតាមកិច្ចសន្យាជាមួយមជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ។ មេធាវីដែលអនុវត្តជំនួយគតិយុត្តិតាមការចាត់តាំងរបស់អង្គការដែលចូលរួមជំនួយគតិយុត្តិ។



អ្នកប្រឹក្សាច្បាប់ដែលមានបទពិសោធន៍ប្រឹក្សាច្បាប់ ០២ ឆ្នាំឡើងទៅ ធ្វើការនៅអង្គការដែលចូលរួមជំនួយគតិយុត្តិ។



សហការីជំនួយគតិយុត្តិ។